

# សិក្ខាសាលា

# ស្ដីពីការផ្សព្វផ្សាយលទ្ធផល និងបិទបញ្ចប់គម្រោង «ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋាន តាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (STA Project)»

## វឌ្ឍនភាពនៃការអភិវឌ្ឍ និងដំណើរការគេហទំព័រថ្មីរបស់ គ.ជ.អ.ប.

NCDD.GOV.KH

**លោក ទី មករា**

មន្ត្រីអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន នៃលេខាធិការដ្ឋាន គ.ជ.អ.ប.

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤

# មាតិកា

១ សេចក្តីផ្តើម

២ គេហទំព័រ គ.ជ.អ.ប.

៣ សមិទ្ធផល

៤ សេចក្តីសន្និដ្ឋាន

៥ បញ្ហាប្រឈម និងទិសដៅបន្ត

# ១. សេចក្តីផ្តើម

**គម្រោង៖ ការពង្រឹងតម្លាភាព និង គណនេយ្យភាពនៅក្នុងអភិបាលកិច្ច មូលដ្ឋានតាមរយៈការចូលរួមរបស់ ប្រជាពលរដ្ឋ**












**Strengthening Transparency and Accountability in Local Governance through Civic Engagement (STA)**

# ១. សេចក្តីផ្តើម (ត)

## សកម្មភាពសំខាន់ៗរបស់គម្រោង

សកម្មភាពទទួលខុសត្រូវសំខាន់ៗរបស់លេខាធិការដ្ឋាន **គ.ជ.អ.ប.** នៅក្នុងការអនុវត្តគម្រោងមានចំនួន៦

### សកម្មភាពទី៥

កែលម្អ និងពង្រីកការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា របស់ **គ.ជ.អ.ប.**

### គោលបំណងនៃសកម្មភាព

ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្នាក់ក្រោមជាតិ (SNA MIS) របស់ **គ.ជ.អ.ប.**

### ការអនុវត្តសកម្មភាព

- បំពាក់ម៉ាស៊ីនមេគាំទ្រដល់ប្រព័ន្ធគ្រប់គ្រងព័ត៌មាន
- កែសម្រួល និងធ្វើបច្ចុប្បន្នភាពគេហទំព័រថ្មី **គ.ជ.អ.ប.** ជាមួយនឹងមុខងារថ្មីផ្ទាំងព័ត៌មាន (Dashboard)

# ២. គេហទំព័រ គ.ជ.អ.ប

## សេចក្ដីផ្ដើម

គេហទំព័ររបស់ គ.ជ.អ.ប. ត្រូវបានរៀបចំ និងដាក់ឱ្យដំណើរការអំឡុងឆ្នាំ២០១០ ក្រោមគំនិតផ្ដួចផ្ដើមដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចក្រឡាហោម ស ខេង អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.**

ដើម្បីកែលម្អ និងធានាបាននូវសុវត្ថិភាពទិន្នន័យខ្ពស់ជាងមុន លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍគេហទំព័រ គ.ជ.អ.ប. ស្ទើរតែទាំងស្រុងទាំងរូបរាង និងបច្ចេកវិទ្យាថ្មី ដើម្បីធានាឱ្យបាននូវសុវត្ថិភាពខ្ពស់ និងមានភាពទាក់ទាញជាងមុន។

## គេហទំព័រថ្មីរបស់ គ.ជ.អ.ប.

គេហទំព័រថ្មី គ.ជ.អ.ប. ត្រូវបានអភិវឌ្ឍន៍ និងដាក់ឱ្យដំណើរការដោយបានរចនាជាមួយបច្ចេកវិទ្យាថ្មី សោភ័ណភាពព័ត៌មានសម្បូរបែប មានភាពបត់បែន ដំណើរការលឿនរហ័ស ងាយស្រួលគ្រប់គ្រង និងអាចចូលទស្សនាតាមរយៈអាសយដ្ឋាន ncdd.gov.kh។

# ២. គេហទំព័រ គ.ជ.អ.ប.(ត)

## វឌ្ឍនភាពនៃគេហទំព័រថ្មីរបស់ គ.ជ.អ.ប.

ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងប្រកបដោយសុវត្ថិភាពខ្ពស់ ភាពងាយស្រួលក្នុងការប្រើប្រាស់ និងមានភាពទាក់ទាញ ស្របតាមសម័យកាលវិវឌ្ឍន៍នៃប្រព័ន្ធបច្ចេកវិទ្យាឌីជីថលបច្ចុប្បន្ន ការរចនាគេហទំព័រថ្មីនេះបានផ្ដោតជាសំខាន់លើរូបរាង (Template) បច្ចេកវិទ្យាថ្មី និងការរចនាដែលមានភាពបត់បែន (Responsive) ដែលអាចប្រើប្រាស់តាមទំហំអេក្រង់ដូចជា ទូរទស្សន៍ឆ្លាតវៃ កុំព្យូទ័រ ថេប្លេត(Tablet) និងទូរស័ព្ទដៃជាដើម។

1



2



# ២. គេហទំព័រ គ.ជ.អ.ប.( ត )

ភាពខុសគ្នាត្រង់ចំណុច " **មាតិកា** " រវាងគេហទំព័រទាំងពីរ មានលក្ខណៈសម្គាល់ដូចខាងក្រោម៖

| គេហទំព័រចាស់នៃ គ.ជ.អ.ប. | | គេហទំព័រថ្មីនៃ គ.ជ.អ.ប. | |
|---|---|---|---|
| ១. ទំព័រដើម | ៦. ដំណឹង/ព្រឹត្តិការណ៍ | ១. ទំព័រដើម | ៦. គម្រោងនានា |
| ២. អំពី គ.ជ.អ.ប. | ៧. គណនេយ្យភាពសង្គម | ២. អំពី គ.ជ.អ.ប. | ៧. គណនេយ្យភាពសង្គម |
| ៣. ប្រជាពលរដ្ឋ | ៨. ទំនាក់ទំនង | ៣. **កម្មវិធីជាតិ** | ៨. ព្រឹត្តិការណ៍ថ្មីៗ |
| ៤. ការផ្តល់សេវា | | ៤. **ផ្ទាំងព័ត៌មាន** | ៩. ទំនាក់ទំនង |
| ៥. ធនធាន និងឯកសារ | | ៥. ធនធាន និងឯកសារ | |

# ២. គេហទំព័រ គ.ជ.អ.ប.( ត )

## ធនធាន និងឯកសារ

- ជាប្រព័ន្ធប្រើសម្រាប់រក្សាទុក និងផ្សព្វផ្សាយឯកសារ គតិយុត្ត និងវីដេអូនានា ពាក់ព័ន្ធកិច្ចការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកិច្ចការងារកំណែទម្រង់សំខាន់ៗផ្សេងទៀត។
- លើកកម្ពស់ការអាន និងជាប្រភពនៃការស្រាវជ្រាវរបស់សិស្សនិស្សិត បញ្ញវ័ន្ត និងសាធារណៈជនទូទៅ។
- ផ្តល់ភាពងាយស្រួលឆាប់រហ័សក្នុងការស្វែងរក និងទាញយកមកប្រើប្រាស់ តាមរយៈប្រព័ន្ធអ៊ីនធឺណិត។
- ការពារនិងថែរក្សាបានយូរអង្វែង ដោយត្រូវបានផ្ទុកនៅក្នុងម៉ាស៊ីនមេ( Server )

library.ncdd.gov.kh

ប្រព័ន្ធគ្រប់គ្រង **បណ្ណាល័យ** អេឡិចត្រូនិច E-Library Database






1

2

# ២.គេហទំព័រ គ.ជ.អ.ប.(ត)

ភាពខុសគ្នាត្រង់ចំណុច "**ផ្នែកគ្រប់គ្រង**" រវាងគេហទំព័រទាំងពីរ មានលក្ខណៈសម្គាល់ដូចខាងក្រោម៖

| គេហទំព័រចាស់នៃ គ.ជ.អ.ប. | គេហទំព័រថ្មីនៃ គ.ជ.អ.ប. |
|---|---|
| ១. មុខងារសំខាន់ៗមួយចំនួនកំពុងដំណើរការដោយគ្មានភាពបត់បែនក្នុងការធ្វើបច្ចុប្បន្នភាពមាតិកា ព័ត៌មាន និងឯកសារពាក់ព័ន្ធ បណ្ណុំរូបភាព ផ្ទាំងរូបភាពចលនា(image carousel)<br>២. ប្រើប្រាស់បច្ចេកវិទ្យា (WordPress)<br>៣. បង្ហោះ(Hosting)គេហទំព័រដោយជួលក្រុមហ៊ុនឯកជន | ១. អាចផ្លាស់ប្តូរ ឬបន្ថែមនូវមុខងារសំខាន់ៗនិងចាំបាច់(Dynamic) មួយចំនួន ដូចជាមាតិកា ព័ត៌មាន និងឯកសារពាក់ព័ន្ធ បណ្ណុំរូបភាព ផ្ទាំងរូបភាពចលនា(Image carousel)<br>២. មានមុខងារដំណើរការលឿនរហ័ស និងមានភាពបត់បែន (Responsive)<br>៣. ប្រើប្រាស់បច្ចេកវិទ្យាថ្មី<br>៤. បង្កើតឱ្យមានប្រព័ន្ធសុវត្ថិភាពខ្ពស់ក្នុងការគ្រប់គ្រង និងប្រតិបត្តិការដោយបង្ហោះត្រង់ពីមជ្ឈមណ្ឌលគ្រប់គ្រង និងរក្សាទិន្នន័យ (Datacenter)របស់លេខាធិការដ្ឋាន គ.ជ.អ.ប. |

# ២. គេហទំព័រ គ.ជ.អ.ប.(ត)

## ផ្ទាំងព័ត៌មាន

ជាផ្នែកមួយពិសេសក្នុងចំណោមផ្នែកសំខាន់នៃគេហទំព័រនេះត្រូវបានបង្កើតឡើងដែលមានមុខងារៈ

១. បម្រើជាមជ្ឈមណ្ឌលកណ្តាលសម្រាប់ធ្វើសន្ទានកម្ម និងបង្ហាញផ្ទាំងព័ត៌មាន (Dashboard)

២. បច្ចុប្បន្នផ្នែកនេះកំពុងដាក់បង្ហាញនូវផ្ទាំងគ្រប់គ្រងព័ត៌មានចំនួនពីរៈ

១



លទ្ធផលការអង្កេតអភិបាលកិច្ច

២

គណនេយ្យភាពសង្គម

ផ្ទាំងព័ត៌មាននៃ SA-M&E Database

រួមមានព័ត៌មានអំពីការអនុវត្តការងារគណនេយ្យសង្គមរបស់រដ្ឋបាល ឃុំ សង្កាត់ សាលាបឋមសិក្សា មណ្ឌលសុខភាពនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ

# ២. គោលនយោបាយ គ.ជ.អ.ប.( ត )

## មុខងារផ្ទាំងព័ត៌មាន

**សន្ទស្សន៍អភិបាលកិច្ច**

0.៦៤
បង្ហូរ

**សន្ទស្សន៍អភិបាលកិច្ច** សំដៅដល់សន្ទស្សន៍សម្រាប់វាស់វែងការលើកកម្ពស់ស្វ័យភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍមូលដ្ឋាន របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានទទួលសិទ្ធិ អំណាចការទទួល ខុសត្រូវ និងសមត្ថភាពក្នុងការអនុវត្តតួនាទី ភារកិច្ចមុខងារដែលស្ថិតក្នុង ដែនសមត្ថកិច្ចរបស់ខ្លួនក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់ក្រុមប្រឹក្សា រដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ។

**សន្ទស្សន៍ការផ្តល់សេវា**

0.៦៩
បង្ហូរ

**សន្ទស្សន៍ការផ្តល់សេវា** សំដៅដល់សន្ទស្សន៍សម្រាប់វាស់វែងកម្រិតនៃការធ្វើឱ្យប្រសើរឡើងនូវគុណ ភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាជូនប្រជាពលរដ្ឋនិងការវាស់វែងកម្រិត នៃការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងតម្រូវការអាទិភាព របស់ប្រជាពលរដ្ឋប្រកបដោយបរិយាបន្ន និងសមធម៌សង្គម។

**សន្ទស្សន៍សមត្ថភាព រដ្ឋបាល ថ្នាក់ក្រោមជាតិ**

N/A
កំពុងបន្ត

**សន្ទស្សន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ** សន្ទស្សន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាការវាស់ស្ទង់គុណភាព នៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងចំណាយសាធារណៈ គុណភាព និងភាពពេញលេញនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ការប្រើប្រាស់ បច្ចេកវិទ្យាឌីជីថល ភាពធន់នឹងហានិភ័យនានា និងការគ្រប់គ្រងការផ្តល់ សេវាសាធារណៈ។ សន្ទស្សន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិកើតចេញ ពីសន្ទស្សន៍រងចំនួន៣គឺ ១). សមត្ថភាពក្របខណ្ឌច្បាប់ ឬក្របខណ្ឌគាំទ្រ ២). សមត្ថភាពស្ថាប័ន និង ៣). សមត្ថភាពធនធានមនុស្ស ។

ផ្ទាំងព័ត៌មានលទ្ធផលការអង្កេតអភិបាលកិច្ច




ផ្ទាំងព័ត៌មាននៃ SA-M&E Database

# ២. គេហទំព័រ គ.ជ.អ.ប.(ត)

## គោលការណ៍ឯកភាព និងដាក់បង្ហោះជាផ្លូវការ

គេហទំព័រថ្មី ត្រូវបានពិនិត្យ សម្រេច និងឯកភាពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥ និងត្រូវបានក្រុមការងារបច្ចេកទេសនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ដាក់បង្ហោះជាផ្លូវការ (Hosting) នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៥ វេលាម៉ោង ៧:០០នាទីព្រឹក។

# ៣. សមិទ្ធផល

## ១ តម្លាភាព

គេហទំព័រ និងមុខងារផ្ទាំងព័ត៌មានថ្មីផ្តល់ឱ្យប្រជាពលរដ្ឋនូវការចូលទស្សនាដោយផ្ទាល់ ដែលនេះជំរុញឱ្យមានតម្លាភាពកាន់តែច្រើន ក្នុងអភិបាលកិច្ចមូលដ្ឋាន និងការបើកចំហទិន្នន័យ(Open Data)។

## ២ ពង្រឹងការគ្រប់គ្រងទិន្នន័យ

គម្រោងនេះបានបង្កើតប្រព័ន្ធដ៏រឹងមាំមួយសម្រាប់ភ្ជាប់គេហទំព័រជាមួយនឹងមូលដ្ឋានទិន្នន័យ SA-M&E ដោយធានាថាទិន្នន័យដែលបានបង្ហាញគឺបច្ចុប្បន្ន និងភាពត្រឹមត្រូវ។

## ៣ ផ្ទាំងព័ត៌មាន

ការផ្តួចផ្តើមឱ្យមានផ្ទាំងព័ត៌មានកាន់តែសំបូរបែប៖ គេហទំព័រនេះបម្រើជាមូលដ្ឋានគ្រឹះសម្រាប់ការរួមបញ្ចូលសំណុំទិន្នន័យបន្ថែម និងផ្ទាំងព័ត៌មាន ដោយពង្រីកវិសាលភាពនៃការចែករំលែកព័ត៌មានជាសាធារណៈបន្ថែមទៀត។

## ៤ ការពង្រឹងសមត្ថភាព

វគ្គបណ្តុះបណ្តាលត្រូវបានធ្វើឡើងដើម្បីធានាថាមន្ត្រីនៃលេខាធិការដ្ឋាន គ.ជ.អ.ប. អាចគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពមាតិកាគេហទំព័រ និងផ្ទាំងព័ត៌មាន។

# ៤. សេចក្តីសន្និដ្ឋាន

សកម្មភាពទី៥ ត្រូវបានបញ្ចប់ដោយជោគជ័យ ដោយផ្តល់នូវឧបករណ៍ និងថ្នាលឌីជីថលដ៏រឹងមាំ មានសមត្ថភាព ប្រសិទ្ធភាព ដែលរួមចំណែកដោយផ្ទាល់ដល់ការសំរេចបាននូវគោលបំណងរបស់គម្រោង STA និងការគាំទ្រដល់លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការអនុវត្តការលើកកម្ពស់ការទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ អំពីសិទ្ធិ ការផ្តល់សេវា និងគម្រោងអភិវឌ្ឍន៍នានានៅមូលដ្ឋាន ត្រូវបានលើកកម្ពស់ប្រកបដោយបរិយាបន្ន និងសមធម៌សង្គម។



# ៥. បញ្ហាប្រឈម និងទិសដៅបន្ត

!!!

## បញ្ហាប្រឈម

- ទាមទារការពង្រឹង និងអភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុក
- តាមដាន ពិនិត្យ និងគាំទ្របច្ចេកទេសជាប្រចាំក្នុង
  អន្តរកាលនេះ
- ទម្រង់អត្ថបទនីមួយៗ នឹងប្រែប្រួលតាមទម្រង់កញ្ចក់
  អេក្រង់នៃឧបករណ៍ប្រើប្រាស់ (computer, laptop,
  Tablet, smart-phone..)
- មុខងារមួយចំនួនទាមទារការកែសម្រួលតាម
  គោលការណ៍នាំបន្ថែម និងបច្ចុប្បន្នភាព

☑

## ទិសដៅបន្ត

- បន្តធ្វើសន្ទានកម្ម និងបង្កើតផ្ទាំងព័ត៌មានជាមួយប្រព័ន្ធគ្រប់គ្រង
  ព័ត៌មានរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់
  ក្រោមជាតិជាបន្តបន្ទាប់
- ប្រមូលមតិអ្នកប្រើប្រាស់សម្រាប់ការកែលម្អ
- បន្តពង្រឹងគុណភាពមាតិកាឲ្យទាន់ពេលវេលា
- បន្តសហការពីគ្រប់ភាគីពាក់ព័ន្ធនានា
- ជំរុញការផ្សព្វផ្សាយ និងលើកកម្ពស់គុណភាពព័ត៌មាន
- តាមដាន ត្រួតពិនិត្យ កែលម្អ និងធ្វើបច្ចុប្បន្នភាពជាប្រចាំលើ
  ប្រភេទព័ត៌មាន ទិន្នន័យ តាមផែនការសកម្មភាពផ្សព្វផ្សាយ

# សូមអរគុណ

